ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់ឱ្យដំណើរការគេហទំព័រផ្លូវការរបស់ អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជន និងវិស័យឯកជនទាំងក្នុង និងក្រៅប្រទេស ជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ឱ្យដំណើរការគេហទំព័រផ្លូវការ និងទំព័រ Facebook របស់អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន (General Department of Public-Private Partnerships) ដែលជាសេនាធិការក្នុងការដឹកនាំ និងគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (ភ.រ.ជ.) នៅព្រះរាជាណាចក្រកម្ពុជា ដែលមានអាសយដ្ឋាន ppp.mef.gov.kh និងទំព័រ Facebook ឈ្មោះ **អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន-gdppp**។

គេហទំព័រនេះមានបង្ហាញជូននូវព័ត៌មានសំខាន់ៗ ដល់សាធារណរួមមាន÷ (១) ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍរៀបចំគម្រោងវិនិយោគសាធារណៈ តាមយន្តការ ភ.រ.ជ. (២) បញ្ជីគម្រោងវិនិយោគសាធារណៈអនុវត្តតាមយន្តការ ភ.រ.ជ. (៣) ដំណើរការកិច្ចលទ្ធកម្មគម្រោង ភ.រ.ជ. (៤) វគ្គបណ្តុះបណ្តាល និង (៥) សកម្មភាព និងវឌ្ឍនភាពផ្សេងៗទៀត។

ដូច្នេះ សូមសាធារណជនទាំងអស់ជ្រាប និងចូលរួមទទួលព័ត៌មានដូចបានរៀបរាប់ខាងលើ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃ ចន្ទ ៧កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២២

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666